ប្រការ ៦ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និងអន្តរជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ និងឯកឧត្តម ដែលមានឈ្មោះក្នុងប្រការ១ ខាងលើ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

***

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០០

**សេចក្តីសំរេច លេខ ៥៣ សសរ**

**ស្តីពី**

**ការបង្កើតគណៈកម្មការអន្តរក្រសួង ទទួលបន្ទុកស្រាវជ្រាវ**
**និងពិនិត្យច្បាប់សមុទ្រ ឆ្នាំ ១៩៨២ (UNCLOS 1982)**

***

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមសំណើរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

**សំរេច**

ប្រការ ១ : បង្កើតគណៈកម្មការអន្តរក្រសួង (Commission ad hoc) ទទួលបន្ទុកស្រាវជ្រាវ និងពិនិត្យច្បាប់សមុទ្រ ឆ្នាំ១៩៨២ ដែលមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១-តំណាង ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ប្រធាន |
| ២-តំណាង ក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ៣-លោក ឈុន ថុល តំណាងខុទ្ទកាល័យនាយករដ្ឋមន្ត្រី | សមាជិក |
| ៤-តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |

| | |
|---|---|
| ៥-តំណាង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៦-តំណាង ក្រសួងយុត្តិធម៌ | សមាជិក |
| ៧-តំណាង ក្រសួងការពារជាតិ | សមាជិក |
| ៨-តំណាង ក្រសួងមហាផ្ទៃ | សមាជិក |
| ៩-តំណាង ក្រសួងបរិស្ថាន | សមាជិក |
| ១០-តំណាង ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ | សមាជិក |
| ១១-តំណាង ក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ១២-តំណាង ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល | សមាជិក |
| ១៣-តំណាង អាជ្ញាធរជាតិព្រំដែន | សមាជិក |
| ១៤-តំណាង អាជ្ញាធរជាតិប្រេងកាត | សមាជិក |
| ១៥-មន្ត្រីការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក (លេខាធិការ) |

ប្រការ ២ : គណៈកម្មការអន្តរក្រសួងនេះមានបេសកកម្មធ្វើការស្រាវជ្រាវ បញ្ហាច្បាប់សមុទ្រអោយបានល្អិតល្អន់ អំពីផលប្រយោជន៍ និងផលវិបាកក្នុងការអនុវត្តន៍ច្បាប់សមុទ្រ ឆ្នាំ ១៩៨២ (UNCLOS 1982) ហើយធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យនិងសំរេចក្នុងការស្នើសុំផ្តល់សច្ចាប័នស្រប តាមមាត្រា២៦ និង៧០ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ដើម្បីបំពេញបេសកកម្មខាងលើ គណៈកម្មការអន្តរក្រសួងនេះមានភារកិច្ចដូចតទៅ :

-ធ្វើទំនាក់ទំនងជាមួយក្រសួងស្ថាប័នដែលពាក់ព័ន្ធ

-សមាជិកនៃគណៈកម្មការ ត្រូវចូលរួមប្រជុំការងារ តាមការអញ្ជើញ របស់ប្រធាន

-គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រា របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្នុងករណីចាំបាច់

ប្រការ ៤ : ក្រសួងស្ថាប័ននីមួយៗ ត្រូវបញ្ជូនឈ្មោះនិងមុខងារនៃតំណាងរបស់ខ្លួន ដូចមានចែងក្នុងប្រការ១ មកប្រធានគណៈកម្មការអន្តរក្រសួងនេះ ដើម្បីសម្របសម្រួលក្នុងការបំពេញភារកិច្ចរបស់គណៈកម្មការ ។

ប្រការ ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ប្រធានអាជ្ញាធរជាតិប្រេងកាត និងនាយកខុទ្ទកាល័យនាយករដ្ឋមន្ត្រី ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន